Washington State Department of Social & Health Services
Transforming lives

# ជំនួយជាប្រាក់ឬជាអាហារ DSHS របស់អ្នក

## Your DSHS Cash or Food Benefits

| ឈ្មោះរបស់អតិថិជន (មេគ្រួសារ) |
|---|
| លេខ ID របស់អតិថិជន |

## ជំនួយជាប្រាក់របស់ក្រសួង DSHS
## ជំនួយប្រាក់ TANF, ប្រាក់ជនភៀសខ្លួន, ប្រាក់ ABD, ប្រាក់បង្វែរ

☐ **គោលបំណង**

ក្រសួង DSHS ផ្ដល់ជំនួយជាប្រាក់ដល់បណ្ដាពលរដ្ឋ ដែលមានប្រាក់ ចំណូលទាប ដែលមានគុណសម្បត្តិទទួលកម្មវិធីជំនួយសាធារណៈ។
ជំនួយទាំងនេះនឹងជួយចេញថ្លៃចំណាយលើជីវភាពរស់នៅជាមូលដ្ឋាន មួយចំនួន (RCW 74.04.770)។

ជំនួយប្រាក់ TANF ត្រូវតែប្រើសម្រាប់តែកូនៗ ដែលស្ថិតក្រោមការបីបាច់របស់អ្នកប៉ុណ្ណោះ។ យើងអាចនឹងតម្រូវឲ្យអ្នកផ្ដល់ភស្តុតាងបញ្ជាក់ថា អ្នកបានប្រើជំនួយប្រាក់ TANF សម្រាប់បំពេញសេចក្ដីត្រូវការទានទាររបស់កូន អ្នកពិតមែន (RCW 74.12.260)។

☐ **ការប្រើប្រាស់ត្រឹមត្រូវ**

អ្នកអាចប្រើជំនួយប្រាក់របស់អ្នក ដើម្បីចេញថ្លៃចំណាយលើជីវភាពរស់នៅ ដូចជា ៖

- ទីជម្រក
- ឥន្ធនៈ
- អាហារ
- ការធ្វើដំណើរដឹកជញ្ជូន
- សំលៀកបំពាក់
- ការថែរក្សាផ្ទះ
- សុខភាពអនាម័យផ្ទាល់ខ្លួន
- ការចំណាយលើការងារ

☐ **ការប្រើប្រាស់ខុសច្បាប់**

នៅក្រោមច្បាប់ RCW 74.08.580, វាគឺជាការខុសច្បាប់ក្នុងការប្រើ**ប័ណ្ណផ្ទេរប្រាក់ជំនួយតាមប្រព័ន្ធអេឡិចត្រូនិច** (EBT) ឬប្រាក់សុទ្ធពីប័ណ្ណ EBT របស់អ្នក ដើម្បី ៖

- លេងល្បែងស៊ីសង។ ការលេងល្បែងស៊ីសងរួមមានការលេងឆោតជាតិ, ភ្នាល់-ថែប, ផាញ់-បជ, ប៊ីងកូ, ប្រណាំងសេះ, ល្បែងទានាក្នុងកាស៊ីណូ, និងល្បែងផ្សងវាសនាទាំងឡាយណា ដែលមានចែងនៅក្នុងច្បាប់ RCW 9.46, 67.16, និង 67.70។
- ទិញសេវាសាក់រូបលើស្បែក, ចោះរន្ធលើដងខ្លួន, ឬទិញរូបគំនូរដងខ្លួនមនុស្សផ្សេងៗ។
- ទិញបារី ឬថ្នាំជក់។
- ទិញគ្រឿងស្រវឹង។
- ទិញរបស់របរ ឬសេវាកម្មអ្វីមួយនៅក្នុង ៖
  - គៀមស្រា។
  - ហាងលក់បៀរ ឬស្រា លុះត្រាតែបានផ្ដល់សិទ្ធិជាអ្នកលក់រាយ SNAP ឬ WIC ។
  - ក្លឹបកំសាន្តក្នុងពេលរាត្រី។
  - ទីភ្នាក់ងារលក់ប័ណ្ណធានា។
  - គ្រឹះស្ថានល្បែងស៊ីសង។
  - ទីកន្លែងសម្ដែងសិល្បៈស្រេបស្រាលសម្រាប់មនុស្សពេញវ័យ។
  - ទីកន្លែងណាមួយ ដែលគេមិនអនុញ្ញាតឲ្យមនុស្សក្រោមអាយុ 18 ឆ្នាំចូល។
    - ឧទាហរណ៍ ឈ្មួញលក់រាយកញ្ឆា ផាកន្លែងដែលកញ្ឆា និង/ឬផលិតផលដែលផែកលើកញ្ឆាត្រូវបានលក់។

## ជំនួយជាអាហាររបស់ក្រសួង DSHS

☐ **គោលបំណង**

កម្មវិធីជំនួយអាហាររបស់ក្រសួង DSHS រួមមាន ៖

- អាហារចាំបាច់ (Basic Food)។
- កម្មវិធីជំនួយអាហារសម្រាប់ជនអន្ដោប្រវេសន៍ស្របច្បាប់ (FAP)។
- គម្រោងដាក់ពាក្យសុំរួមរបស់រដ្ឋវ៉ាស៊ីនតោន (WASHCAP)។
- ជំនួយអាហារអន្តរកាល (TFA)។

កម្មវិធីទាំងនេះផ្ដល់ជំនួយដល់បណ្ដាមនុស្ស ដែលមានប្រាក់ចំណូលទាប ដើម្បីទិញមប ដោយប្រើប័ណ្ណផ្ទេរប្រាក់ជំនួយតាមប្រព័ន្ធអេឡិចត្រូនិច (EBT)។

☐ **ការប្រើប្រាស់ត្រឹមត្រូវ**

អ្នក និងក្រុមគ្រួសាររបស់អ្នក អាចប្រើជំនួយអាហាររបស់អ្នក ដើម្បីទិញអាហារពីហាងលក់អាហារណា ដែលបានអនុញ្ញាតដោយ**ទាយកដ្ឋានសេវាអាហារ និងអាហារូបត្ថម្ភ** (FNS) របស់ក្រសួង USDA។

អ្នកអាចប្រើជំនួយរបស់អ្នក ដើម្បីទិញ ៖

- នំបុ័ង និងនំសៀរៀល។
- ផ្លែឈើ និងបន្លែ។
- ឈីស, ទឹកដោះគោ, និងផលិតផលអាហារដែលធ្វើពីទឹកដោះគោ។
- សាច់គោជ្រូក, ត្រី, សាច់សត្វស្លាប, និងពងសត្វស្លាប។
- អាហារស្ទើរគ្រប់មុខទាំងអស់ លើកលែងតែអាហារចម្អិនក្ដៅៗ។
- គ្រាប់ពូជ និងកូនឈើដែលបង្កើតផលផ្លែ។

☐ **ការប្រើប្រាស់ខុសច្បាប**

វាមិនត្រូវច្បាប់ទេ ប្រសិនបើអ្នក ៖

- ប្រើជំនួយអាហារដើម្បីទិញវត្ថុអ្វីមួយក្រៅពីអាហារ សម្រាប់សមាជិកគ្រួសារទាំងអស់ ដែលមានលក្ខណសម្បត្តិទទួលជំនួយនេះ។
- លក់ឬព្យាយាមលក់ប័ណ្ណ EBT របស់អ្នក។
- យកជំនួយ ឬអាហារដែលអ្នកទិញបានពីប័ណ្ណ EBT របស់អ្នក ទៅប្ដូរយកវត្ថុមានតម្លៃផ្សេងៗ(ពីការជួញដូរខុសច្បាប់ជាដើម)។ ឧទាហរណ៍អំពីការជួញដូរខុសច្បាប់រួមមានទូរការយកអាហារ ទៅប្ដូរយកប្រាក់សុទ្ធ, ថ្នាំញៀន, ឬអាវុធផ្សេងៗ។
- ឲ្យជំនួយរបស់អ្នកទៅមនុស្សណាម្នាក់ ដែលពុំមែនជាសមាជិកគ្រួសាររបស់អ្នក។
- ប្រើជំនួយអាហារ ដើម្បីទិញវត្ថុអ្វីមួយ ដែលមិនមែនជាអាហារ។ ឧទាហរណ៍អំពីវត្ថុដែលមិនមែនជាអាហាររួមមាន ៖ បារី, ថ្នាំជក់, បៀរ, ស្រា, គ្រឿងស្រវឹង, របស់ប្រើប្រាស់ក្នុងគ្រួសារ, សាប៊ូ, ផលិតផលធ្វើពីក្រដាស, ថ្នាំវីតាមីន, ថ្នាំពេទ្យ, ឬចំណីសត្វ។
- ប្រើផលប្រយោជន៍អាហាររបស់អ្នកដើម្បីបង់គណនីឥណទាន ។



Barcode label

14520

## ជំនួយជាប្រាក់របស់ក្រសួង DSHS
**ជំនួយប្រាក់ TANF, ប្រាក់ជនភៀសខ្លួន, ប្រាក់ PWA, ប្រាក់ ABD, ប្រាក់បង្វែរ**

☐ **ទោសបញ្ញត្តិសម្រាប់ការប្រើប្រាស់ខុសច្បាប់**

ប្រសិនបើអកប្រើប័ណ្ណ EBT របស់អក ឬប្រាក់សុទ្ធពីប័ណ្ណ EBT របស់អក ដោយខុសច្បាប់ ឬដោយមិនត្រឹមត្រូវ, នោះយើងអាចនឹង ៖

- ចាត់តាំងឲ្យមានអកការពារមោក់ ដើម្បីគ្រប់គ្រងប្រាក់ជំនួយរបស់អក។
- តម្រូវឲ្យអកផ្តល់ភស្តុតាងបញ្ជាក់ថា អកប្រើប្រាក់ជំនួយរបស់អក សម្រាប់ កូនៗ ដែលស្ថិតក្រោមការបីបាច់របស់អក។
- បញ្ឈប់ប្រាក់ជំនួយរបស់អក។
- អនុវត្តវិធានការផ្លូវច្បាប់, ដោយរួមទាំងការប្តឹងចោទអំពីបទឧក្រិដ្ឋផង។

☐ **ថ្លៃម៉ាស៊ីនដូរប្រាក់ស្វ័យប្រវត្ត (Automated Teller machine, ATM) សម្រាប់ការដកប្រាក់ចេញពីប័ណ្ណ EBT របស់អក**

នៅពេលអកប្រើប័ណ្ណ EBT របស់អក ដើម្បីដកយកប្រាក់នៅតាមម៉ាស៊ីន ATM, នោះ ៖

- មាស់ម៉ាស៊ីន ATM ឬធនាគារក៏នឹងយកថ្លៃប្រើប្រាស់ សម្រាប់ការកដ ប្រាក់ណាមួយរបស់អក។
- ក្រសួងមិនធ្វើការបង់ប្រាក់សំរាប់ការទារប្រាក់មកវិញនៃការបង់ថ្លៃម៉ាស៊ីន ATM នោះទេ
- អកប្រហែលជាអាចសុំដូរប្រាក់ពីហាងលក់ទំនិញខ្លះ ដោយមិនអស់ថ្លៃ។

## ជំនួយជាអាហាររបស់ក្រសួង DSHS

☐ **ទោសបញ្ញត្តិសម្រាប់ការប្រើប្រាស់ខុសច្បាប់**

ប្រសិនបើអកមានចេតនាប្រើប្រាស់ជំនួយរបស់អកដោយខុសច្បាប់, នោះ អកអាចនឹង ៖

- ត្រូវបានតម្រូវអោយបង់ប្រាក់ឡើងវិញនូវរាល់គុនប្រយោជន៍ ដែលបាន អោយ
- អស់គុណសម្បត្តិទទួលជំនួយ ព្រមទាំងនឹងបាត់បង់ជំនួយរបស់អក ៖
    - អស់រយៈពេលយ៉ាងតិចណាស់មួយឆាំ។
    - រហូតអស់មួយជីវិត។
    - នៅតែអស់គុណសម្បត្តិ បើទោះណាជាអកបានរើទៅរស់នៅ រដ្ឋផ្សេងក៏ដោយ។
- ត្រូវផាកពិន័យជាប្រាក់។
- ត្រូវទទួលរងចំណាត់ការផ្លូវច្បាប់ ដោយរួមទាំងការប្តឹងចោទអំពីបទ ឧក្រិដ្ឋផង។ ក្រសួង DSHS នឹងធ្វើសហការជាមួយអាជ្ញាធរថាក់រដ្ឋ, ថាក់មូលដ្ឋាន, និងថាក់សហព័ន្ធ ដើម្បីប្តឹងចោទអំពីបទជួញដូរជំនួយ អាហារខុសច្បាប់។

តាមរយៈការចុះហត្ថលេខាខាងក្រោមនេះ, ខ្ញុំយល់ស្របថា ការប្រើជំនួយប្រាក់ និងជំនួយអាហាររបស់ក្រសួង DSHS បានត្រូវគេពន្យល់ប្រាប់ខ្ញុំសព្វគ្រប់ហើយ។ ខ្ញុំបាន យល់អំពីការប្រើជំនួយត្រឹមត្រូវ និងទោសបញ្ញត្តិសម្រាប់ការប្រើជំនួយខុសច្បាប់។ ខ្ញុំយល់ថា លក្ខណសម្បត្តិរបស់ខ្ញុំ សម្រាប់ជំនួយ DSHS នឹងពុំមានផលប៉ះពាល់ទេ ប្រសិនបើខ្ញុំមិនចុះហត្ថលេខាលើទម្រង់នេះ។ អស់អកដែលមិនចុះហត្ថលេខាលើទម្រង់នេះគឺនៅតែជាកម្មវត្ថុ ដែលត្រូវស្ថិតក្រោមបទបញ្ញត្តិនៃកម្មវិធីនេះ ឬទោសបញ្ញត្តិនៃ បទឧក្រិដ្ឋ សម្រាប់ការប្រើជំនួយខុសច្បាប់ទាំងអស់។

ខ្ញុំយល់ថា ប័ណ្ណ EBT របស់ខ្ញុំបានផ្តល់ជូនក្រសួង DSHS នូវប្រវត្តិនៃការដូរប្រាក់របស់ខ្ញុំ ដោយសរុបទាំងទីកន្លែងដែលខ្ញុំបានប្រើប័ណរបស់ខ្ញុំ ដើម្បីដូរប្រាក់ផង។ ខ្ញុំ យល់ថា ប្រសួង DSHS នឹងប្រើព័ត៌មាននេះ និងប្រវត្តិនៃការសើសុំប័ណ្ណជំនួសថ្មីទាំងប៉ុន្មានរបស់ខ្ញុំ ដើម្បីធ្វើការស៊ើបអង្កេតអំពីការប្រើជំនួយប្រាក់ ឬជំនួយអាហារខុស ច្បាប់ទានា។

| ហត្ថលេខារបស់អកដាក់ពាក្យសុំ | កាលបរិច្ឆេទ |
|---|---|
| | |

☐ បានបដិសេធ មិនចុះហត្ថលេខា; ឈ្មោះបុគ្គលិកនៃក្រសួង DSHS ជាអក្សរកាត់ ___________